# ក

## មាតិកា

***

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៥៨ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មជូនលោក ហេ យ៉ុងផាក (HAE YOUNG PARK) សញ្ជាតិដើមកូរ៉េ ១៥៩៣
- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៥៩ ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិត្តិបត្តាមរណៈ ជូនចំពោះសពលោកឧត្តមសេនីយ៍ត្រី ហ៊ុន ចណ្ណា ១៥៩៤
- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦០ ស្តីពីការបង្កើតអាជ្ញាធរ កម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ១៥៩៥
- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦១ តែងតាំងសមាសភាព អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ១៥៩៩
- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦២ តែងតាំងឯកឧត្តម ហ៊ុយ ចាន់នី ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ១៦០០
- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦៣ កំណត់យកថ្ងៃទី០៨ ខែកញ្ញា ជារៀងរាល់ឆ្នាំ ជាទិវាអក្ខរកម្មជាតិ ១៦០១
- ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦៤ តម្លើងអ្នកអង្គម្ចាស់ ស៊ី សុវត្ថិ សិរីវឌ្ឍន៍ ជាព្រះអង្គម្ចាស់ ១៦០២

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

០៤-៩-២០០០ - អនុក្រឹត្យ លេខ ៦២ អនក្រ.បក ស្តីពីការកែសម្រួល អនុក្រឹត្យ លេខ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ១៩៩៨ និងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ ១៦០៣

០៤-៩-២០០០ - អនុក្រឹត្យ លេខ ៦៣ អនក្រ.បក ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈ ភាពយន្ត និងវីដេអូ ១៦០៦

០៤-៩-២០០០ - អនុក្រឹត្យ លេខ៦៤ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០១ ១៦១៣

០៤-៩-២០០០ - អនុក្រឹត្យលេខ ៣៣៨ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ១៦១៥

០៤-៩-២០០០ - អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ១៦១៦

០៣-៩-២០០០ - អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៧

០៤-៩-២០០០ - អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៧

០៤-៩-២០០០ - អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៩

០៨-៩-២០០០ - អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៩

## ២-សេចក្តីសំរេច

០៤-៩-២០០០ - សេចក្តីសំរេច លេខ ៥៨ សសរ ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល ១៦២១

០៨-៩-២០០០ - សេចក្តីសំរេច លេខ ៥៩ សសរ ស្តីពីការបង្កើតគណៈកម្មការដើម្បី ទប់ស្កាត់ទឹកជំនន់ ១៦២១

# គ

## ៣-សារាចរ

០៥-៩-២០០០ - សារាចរ លេខ ០២ សរ ស្តីពីការចាត់ចែងរៀបចំពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគំរប់ព្រះជន្ម ៧៨ យាងចូល ៧៩ព្រះវស្សា បុណ្យខួបលើកទី៤៧ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ១៦២៣

## III-ការងារបណ្តាក្រសួង

### លិខិតបទដ្ឋានគតិយុត្ត (ការងារ) ក្រសួងអប់រំ យុវជន និងកីឡា

០១-០៩-២០០០ - ប្រកាស លេខ ៩៦៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យព្នៅ ស្ថិតនៅក្នុងឃុំ ព្នៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។ ១៦២៧

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៥៨

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១ .- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក ហេ យ៉ុងផាក (HAE YOUNG PARK) សញ្ជាតិដើមកូរ៉េ (សាធារណរដ្ឋកូរ៉េ) កើតថ្ងៃទី ០៧ ខែតុលា ឆ្នាំ ១៩៥២ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

# ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៥៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព ៖

-លោក ឧត្តមសេនីយ៍ត្រី ហុង ទណ្ឌា អត្តលេខ ០០០២០៩ នាយករង នាយកដ្ឋាន នយោបាយ និងផែនការ

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

# ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦០

## ស្តីពី

## ការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការហាមប្រើប្រាស់គ្រាប់មីនប្រឆាំងប្រាណមនុស្ស

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលខ្លឹមសារ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

-បានទ្រង់យល់ការក្រាបបង្គំទូលស្នើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

## ត្រាស់បង្គាប់

## ជំពូកទី ១

## នីតិសារជាតិ នៃ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

មាត្រា ១ .- ត្រូវបានបង្កើត អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដែលមានអក្សរកាត់ អ.ក.គ.ម.ស.ព.ម. ។ អ.ក.គ.ម.ស.ព.ម. ស្ថិតនៅក្រោមការដឹកនាំផ្ទាល់នៃនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

## ជំពូកទី ២
## តួនាទី និង ភារកិច្ច

មាត្រា ២ .- អ.ក.ត.ម.ស.ព.ម. មានតួនាទី : គ្រប់គ្រងរាល់សកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែល នៅសេសសល់ក្នុងដី និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ក្នុងព្រះរាជាណាចក្រកម្ពុជា ។ អ.ក.ត.ម.ស.ព.ម. ជាស្ថាប័នជាតិតែមួយគត់ តំណាងអោយរាជរដ្ឋាភិបាលកម្ពុជានៅរាល់កិច្ចប្រជុំអន្តរជាតិ ស្តីពីសកម្មភាពមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ។ អ.ក.ត.ម.ស.ព.ម. តំណាងអោយរាជរដ្ឋាភិបាល ចុះហត្ថលេខាលើរាល់កិច្ចព្រមព្រៀង លើពិធីសារ លើកិច្ចសន្យាទាំងឡាយ នៃជំនួយទ្វេភាគី ស្តីពីសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងកិច្ចសង្គ្រោះជនពិការដោយសារគ្រាប់មីន ។

មាត្រា ៣ .- អ.ក.ត.ម.ស.ព.ម. មានភារកិច្ចដូចតទៅ :

ក.រៀបចំគោលនយោបាយ ស្តីពីសកម្មភាពកំចាត់មីន និង និងយុទ្ធភ័ណ្ឌដែលនៅសេសសល់ក្នុងដីមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន

ខ-រៀបចំចក្ខុវិស័យជាយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែង នៃសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ។

គ-រៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ នៃសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ឃ-សំរបសំរួលនូវរាល់សកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ។

ង តាមដាន និងត្រួតពិនិត្យការងារនៃសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ដើម្បីអោយគ្រប់អង្គភាពជាតិ និងអន្តរជាតិប្រតិបត្តិករនានា អនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល

ច-ស្វែងរកប្រភពធនធាន ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុង និងក្រៅប្រទេស

ឆ-បញ្ជាអោយកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលនៅមាន និងរកឃើញ

ជ-ចេញបទប្បញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តន៏សកម្មភាពប្រឆាំង និងកំចាត់មីន

ឈ-ផ្តល់អាជ្ញាប័ណ្ណដល់រាល់អង្គភាពកំចាត់មីនជាតិ និងអន្តរជាតិនានា ដែលធ្វើសកម្មភាពបោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា

ញ-មានសិទ្ធដកហូតអាជ្ញាប័ណ្ណ ពីអង្គភាពកំចាត់មីនជាតិ និងអន្តរជាតិនានា ដែលធ្វើសកម្មភាពបោសសំអាតមីនក្នុងព្រះរាជាណាចក្រកម្ពុជា

ង-គ្រប់គ្រងទិន្នន័យ និងបណ្ណាល័យរបស់រាល់តំបន់ឯកសារដែលទាក់ទងនឹងបញ្ហាមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងកិច្ចសង្គ្រោះជនពិការដោយសារគ្រាប់មីន

ច-រៀបចំគោលនយោបាយ ស្តីពីការប្រើប្រាស់ដីធ្លី ដែលត្រូវបានបោសសំអាតមីនរួចហើយ និងត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយនេះ

ឆ-គ្រប់គ្រងអនុវត្តន៍ នូវច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និងអនុសញ្ញាអូតាវ៉ា ស្តីពីការហាមប្រាមការប្រើប្រាស់ រក្សាទុក ផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល

ជ-តាមដាន ពិនិត្យ និងផ្តល់ការណែនាំក្នុងការប្រើប្រាស់ថវិកា និងសំភារៈបរិក្ខារដែលផ្តល់ដោយជំនួយរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ នៃបណ្តាអង្គភាពបោសសំអាតមីនជាតិ និងអន្តរជាតិទាំងអស់ ដែលមានសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា ៨ .- អ.ក.គ.ម.ស.ព.ម. មានសមាសភាពដូចតទៅ :

| | |
|---|---|
| -នាយករដ្ឋមន្ត្រី | ជាប្រធាន |
| -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| -ឥស្សរជនជាន់ខ្ពស់ ១ រូប | ជាអគ្គលេខាធិការ |
| -តំណាងក្រសួងការបរទេស | ជាសមាជិក |
| -តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| -តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា | ជាសមាជិក |
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| -តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| -តំណាងក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ | ជាសមាជិក |
| -ឥស្សរជនជាន់ខ្ពស់ជំនាញច្បាប់ ១ រូប | ជាសមាជិក |

មាត្រា ៥ .- ក្រៅពីប្រធាន និងអនុប្រធាន សមាសភាព អ.ក.គ.ម.ស.ព.ម. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ទៅតាមករណីសមាជិកម្នាក់ៗ តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី ។ អាណត្តិរបស់សមាជិក អ.ក.គ.ម.ស.ព.ម.រយៈពេល៥ឆ្នាំ ។ នាយករដ្ឋមន្ត្រីអាចស្នើសុំការតែងតាំងសមាសភាពសមាជិកបន្ថែមទៀតបាន ។

មាត្រា ៦ .- អ.ក.គ.ម.ស.ព.ម. មានភារកិច្ច គ្រប់គ្រង អនុម័តសំរេច លើរាល់គំរោងផែនការ និងសកម្មភាពនានា ដើម្បីធានានូវប្រសិទ្ធភាព និងតម្លាភាពក្នុងការអនុវត្តនូវរាល់ភារកិច្ច ដូចមានចែងក្នុង មាត្រា២ នៃព្រះរាជក្រឹត្យនេះ ។

មាត្រា ៧ .- អ.ក.គ.ម.ស.ព.ម. រួមប្រជុំ ៣ខែម្តង តាមការកោះអញ្ជើញរបស់ប្រធាន ដែលជាអ្នកកំណត់របៀបវារៈ ។ ពានការប្រគល់សិទ្ធរបស់ប្រធាន អនុប្រធានអាចកោះប្រជុំ និងកំណត់របៀបវារៈ នៃសម័យប្រជុំ អ.ក.គ.ម.ស.ព.ម. ។

មាត្រា ៨ .- អ.ក.គ.ម.ស.ព.ម. មានគណៈអចិន្ត្រៃយ៍មួយ ដែលមានសមាសភាព ប្រធាន អនុប្រធាន និងអគ្គលេខាធិការ និងដែលមានសិទ្ធិអនុម័តសំរេចលើរាល់ករណី ។

មាត្រា ៩.- អគ្គលេខាធិការ អ.ក.គ.ម.ស.ព.ម. មានភារកិច្ចដឹកនាំ និងបំពេញការងារ អ.ក.គ.ម.ស.ព.ម.ប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព ។ អគ្គលេខាធិការ អ.ក.គ.ម.ស.ព.ម ត្រូវតែងតាំងហើយព្រះរាជក្រឹត្យសំរាប់រយៈពេល ៥ឆ្នាំ រួចអាចបន្តទៀតបាន ដោយមានការស្នើ ពីនាយករដ្ឋមន្ត្រី ។

មាត្រា ១០ .- នាយករដ្ឋមន្ត្រី អាចតែងតាំង អគ្គលេខាធិការរងពីររូប ជាជំនួយការអគ្គលេខាធិការ : មួយរូបទទួលបន្ទុកកិច្ចការសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងមួយរូបទៀតទទួលបន្ទុកកិច្ចការ សង្គ្រោះ ជនពិការដោយសារមីន ។ អគ្គលេខាធិការរងត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ១១ .- អ.ក.គ.ម.ស.ព.ម. មានអគ្គលេខាធិការដ្ឋានមួយ និងអង្គភាពមួយចំនួនទៀតតាមការចាំបាច់ នៃការបំពេញការងារទូទៅរបស់ អ.ក.គ.ម.ស.ព.ម. ។

មាត្រា ១២ .- ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងភារកិច្ចលំអិតទូទៅរបស់ អ.ក.គ.ម.ស.ព.ម. និងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយឡែក ដោយអនុក្រឹត្យ ។

មាត្រា ១៣ .- អ.ក.គ.ម.ស.ព.ម. មានសិទ្ធិប្រើប្រាស់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ១៤ .- ដើម្បីដំណើរការសកម្មភាពរបស់ខ្លួន អ.ក.គ.ម.ស.ព.ម. ត្រូវមានខ្ទង់ថវិកាមួយ ដែលភ្ជាប់ជាមួយថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៤

## ប្រភពធនធាន

មាត្រា ១៥ .- ប្រភពធនធាន អ.ក.គ.ម.ស.ព.ម. ត្រូវបានមកពី :

-ថវិការាជរដ្ឋាភិបាលកម្ពុជា

-ជំនួយពីសហគមន៍អន្តរជាតិ និង អង្គការផ្តល់ជំនួយនានា

-ប្រាក់ចំណូលបានមកពីសេវាកម្មផ្សេងៗ ផ្តល់ដោយអង្គការសាធារណៈ ឬ ឯកជន ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៦ .- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច ព្រះរាជក្រឹត្យនេះ។

មាត្រា ១៨ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលខ្លឹមសារ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

-បានទ្រង់យល់ការក្រាបបង្គំទូលស្នើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងសមាភាព អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន អក្សរកាត់ អ.ក.គ.ម.ស.ព.ម. ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-សម្ដេច | ហ៊ុន សែន | ជាប្រធាន |
| ២-ឯកឧត្ដម | ស៊ុខ អាន | ជាអនុប្រធាន |
| ៣-ឯកឧត្ដម | សម សុគ្គា | ជាអគ្គលេខាធិការ |
| ៤-ឯកឧត្ដម | អ៊ិត សំហេង | ជាសមាជិក |
| ៥-ឯកឧត្ដម | អ៊ុង គីមអន | ជាសមាជិក |
| ៦-ឯកឧត្ដម | ព្រុំ សុខា | ជាសមាជិក |
| ៧-ឯកឧត្ដម | ឈៀង យ៉ាណារ៉ា | ជាសមាជិក |
| ៨-ឯកឧត្ដម | អ៊ិត ឈន | ជាសមាជិក |
| ៩-ឯកឧត្ដម | ឡេង ម៉េងឃ្វិន | ជាសមាជិក |
| ១០-ឯកឧត្ដម | [illegible] | ជាសមាជិក |
| ១១-ឯកឧត្ដម | ឡូសែក សេដ្ឋា | ជាសមាជិក |

មាត្រា ២ .- រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .-នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

***

## ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦២

យើង

ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០០

## ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម ហ៊ុយ ចាន់ធី ជាអគ្គាធិការនៃអាគារធិការដ្ឋាន នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

## ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦៣

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ .- កំណត់យកថ្ងៃទី០៨ ខែ កញ្ញា រៀងរាល់ឆ្នាំ ជាទិវាអក្ខរកម្មជាតិ ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៩០០/១៦៤**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

* * *

**តម្លើង**

**អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន**

**ជា**

**ព្រះអង្គម្ចាស់**

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០០

★★★

# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៦២ អនក្រ.បក

### ស្តីពី

### ការកែសំរួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៨ និងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ

***

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកត/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកត/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-យោងតាមសំណើរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**សំរេច**

**មាត្រា ១ .-**

បង្កើតគណៈកម្មការប្រឹក្សាការងារមួយនៅអមក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលមានបេសកកម្មជាអាទិ៍ សិក្សាស្រាវជ្រាវរាល់បញ្ហាដែលទាក់ទង និងការងារ មុខរបរនៃកម្មករ និយោជិត ប្រាក់ឈ្នួល ការអប់រំវិជ្ជាជីវៈ ចលនាកំលាំងពលកម្មក្នុងប្រទេស សន្តិរប្រវេសន៍ ការរៀបចំអោយរឹតតែប្រសើរឡើងនូវលក្ខខណ្ឌខាងសំភារៈ និងខាងស្មារតី នៃកម្មករ និយោជិត ហើយនិងបញ្ហាអនាម័យ និងសន្តិសុខការងារ ។

**មាត្រា ២ .-**

គណៈកម្មការប្រឹក្សាការងារមានភារកិច្ចជាអាទិ៍ដូចតទៅ :

-លើកយោបល់ណែនាំអំពីអត្រាប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានា

-ផ្តល់យោបល់ជាមុន ដើម្បីពង្រីកដែនអនុវត្តនៃអនុសញ្ញារួម ឬក្នុងករណីដែលគ្មានអនុសញ្ញារួមទេ ផ្តល់យោបល់ជាយថាហេតុ ជាមុនចំពោះបទបញ្ញានៃលក្ខខណ្ឌមុខរបរនៅក្នុងវិជ្ជាជីវៈមួយ ឬក្នុងវិស័យសកម្មភាពណាមួយជាក់លាក់ ។

**មាត្រា ៣ .-**

គណៈកម្មការប្រឹក្សាការងារមានសមាសភាពដូចតទៅ :

-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬ តំណាង ជាប្រធាន

| | |
|---|---|
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មួយរូបជាសមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | មួយរូបជាសមាជិក |
| -តំណាងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | មួយរូបជាសមាជិក |
| -តំណាងក្រសួងសុខាភិបាល | មួយរូបជាសមាជិក |
| -តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | មួយរូបជាសមាជិក |
| -តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | មួយរូបជាសមាជិក |
| -តំណាងក្រសួងបរិស្ថាន | មួយរូបជាសមាជិក |
| -តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | មួយរូបជាសមាជិក |
| -តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មួយរូបជាសមាជិក |
| -តំណាងអង្គការសហជីព កម្មករ និយោជិត ដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ | ប្រាំរូបជាសមាជិក |
| -តំណាងអង្គការនិយោជក ដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ | ប្រាំរូបជាសមាជិក |

គណៈកម្មការនេះត្រូវបោះឆ្នោតជ្រើសរើសអនុប្រធានពីររូប គឺម្នាក់ ក្នុងចំណោម ៥នាក់ ដែលជាតំណាងនៃអង្គការសហជីពកម្មករ និយោជិត និងម្នាក់ទៀតក្នុងចំណោម៥នាក់ ដែលជាតំណាងអង្គការនិយោជក ។

នីតិវិធីនៃការបោះឆ្នោតជ្រើសរើសអនុប្រធានគណៈកម្មការប្រឹក្សាការងារត្រូវអនុវត្តដូចតទៅ :

-អនុប្រធានមួយរូបនៃគណៈកម្មការប្រឹក្សាការងារ ដែលមកពីអង្គការសហជីព កម្មករ និយោជិត ត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកទាំងប្រាំរូប នៃភាគីតំណាងអង្គការសហជីព កម្មករ និយោជិត ។

-អនុប្រធានមួយរូបទៀតនៃគណៈកម្មការប្រឹក្សាការងារ ដែលមកពីអង្គការនិយោជក ត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកទាំងប្រាំរូប នៃភាគីតំណាងនិយោជក ។

មាត្រា ៤ .-

គណៈកម្មការប្រឹក្សាការងារត្រូវមានសមាជិកបំរុង ដែលមានចំនួនស្មើនឹងចំនួនសមាជិកពេញសិទ្ធិ ។

សមាជិកពេញសិទ្ធិ និងសមាជិកបំរុងរបស់គណៈកម្មការប្រឹក្សាការងារ ដែលឧទ្ទេសនាមដោយក្រសួងពាក់ព័ន្ធ ដោយអង្គការសហជីពកម្មករ និយោជិត និងអង្គការ និយោជក ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ គណៈកម្មការប្រឹក្សាការងារអាចអញ្ជើញតំណាងក្រសួង និងស្ថាប័ន អង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធផ្សេងៗទៀតចូលរួមប្រជុំ ដើម្បីផ្តល់យោបល់ក្នុងករណីចាំបាច់ ។

មាត្រា ៥ .-

សមាជិកគណៈកម្មការប្រឹក្សាការងារត្រូវមានអាណត្តិមួយឆ្នាំ ។ សមាជិកបំរុងត្រូវចូលរួមប្រជុំជំនួសសមាជិកពេញសិទ្ធិដែលអវត្តមាន ។ ករណីដែលសមាជិកពេញសិទ្ធិទទួលមរណភាព លាលែង ដកហូត ឬផ្លាស់ប្តូរពីតំណែងដោយប្រការណាមួយ ដោយក្រសួង ឬអង្គការពាក់ព័ន្ធ សមាជិកបំរុង និងក្លាយជាសមាជិកពេញសិទ្ធិដោយស្វ័យប្រវត្តិរហូតដល់ចប់អាណត្តិ ។ ក្នុងរយៈពេលនេះក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចស្នើអោយក្រសួង ឬ អង្គការពាក់ព័ន្ធឧទ្ទេសនាមបេក្ខជនថ្មីជំនួសសមាជិកបំរុងមុន បើពិនិត្យឃើញថាចាំបាច់ ។

មាត្រា ៦ .-

លិខិតអញ្ជើញចូលរួមប្រជុំ និងឯកសារត្រៀមត្រូវផ្ញើជូនសមាជិកពេញសិទ្ធិ និងសមាជិកបំរុង យ៉ាងយឺតបំផុត ១៥ថ្ងៃ មុនសម័យប្រជុំ ។ កំណត់ហេតុនៃការប្រជុំត្រូវចុះហត្ថលេខាដោយប្រធាន និងអនុប្រធានគណៈកម្មការ ហើយត្រូវផ្ញើជូនសមាជិកពេញសិទ្ធិ និងសមាជិកបំរុងទាំងអស់ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយថ្ងៃប្រជុំ ។

មាត្រា ៧ .-

គណៈកម្មការប្រឹក្សាការងារត្រូវរួមប្រជុំពីរដងយ៉ាងតិចក្នុងមួយឆ្នាំ ។ ប្រធានគណៈកម្មការប្រឹក្សាការងារអាចកោះប្រជុំគណៈកម្មការនេះបានគ្រប់ពេលទៅតាមការយល់ឃើញរបស់ខ្លួន ឬទៅតាមសំណើរបស់អនុប្រធានណាមួយ ។ ការកោះប្រជុំវិសាមញ្ញ ដែលស្នើដោយអនុប្រធានណាមួយនៃគណៈកម្មការអាចធ្វើទៅបានលុះត្រាតែបានបញ្ជាក់ពីហេតុផលសមស្រប និងការចាំបាច់ ។ ក្នុងករណីឯកភាព ប្រធានគណៈកម្មការត្រូវរៀបចំរបៀបវារៈនៃសម័យប្រជុំវិសាមញ្ញ ដោយពិគ្រោះយោបល់ជាមួយអនុប្រធានទាំងពីរ ។ ការប្រជុំវិសាមញ្ញត្រូវធ្វើក្នុងអំឡុង៣០ថ្ងៃយ៉ាងយូរ ក្រោយការរៀបចំរបៀបវារៈ ។

មាត្រា ៨ .-

ការសំរេចលើបញ្ហាអ្វីមួយ ក្នុងនោះមានរួមបញ្ចូលទាំងការបោះឆ្នោតជ្រើសរើសអនុប្រធានគណៈកម្មការផង ត្រូវអនុម័តយកតាមសំឡេងភាគច្រើននៃចំនួនសមាជិកដែលបានបោះឆ្នោត ។ ករណីទទួលបានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមភាព ។

ការបោះឆ្នោតត្រូវធ្វើឡើងជាចំហរ លើកលែងតែការបោះឆ្នោត ដើម្បីជ្រើសរើសអនុប្រធានគណៈកម្មការដែលត្រូវធ្វើដោយសំងាត់ ។

**មាត្រា ៩ .-**

គណៈកម្មការប្រឹក្សាការងារត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលរ៉ាប់រងដោយ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**មាត្រា ១០ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងគ្រប់អង្គភាពវិជ្ជាជីវៈដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាល

វិជ្ជាជីវៈ និងយុវនីតិសម្បទា

**ហត្ថលេខា**

**អ៊ិត សំហេង**

★★★

# អនុក្រឹត្យ លេខ ៦៣ អនក្រ.បក

## ស្តីពី

## ការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០០

**សំរេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត វីដេអូ ព្រមទាំងផ្តល់ការលើកទឹកចិត្តផលិតកម្មភាពយន្ត និងវីដេអូក្នុងប្រទេសដើម្បីថែរក្សា ការពារវប្បធម៌ជាតិ ធានាផល់ការគោរពសីលធម៌សង្គម ។

មាត្រា ២ .-

ការគ្រប់គ្រង និងការបង្ក្រាបបទល្មើសភាពយន្ត វីដេអូ សំដៅលើការត្រួតពិនិត្យការផលិត ផ្សព្វផ្សាយត្រួតពិនិត្យការធ្វើអាជីវកម្មតាមគ្រប់មធ្យោបាយនូវ សិល្បៈទី៧ មានស្នាដៃភាពយន្ត និងស្នាដៃវីដេអូដែលមានទម្រង់ផ្សេងៗដូចជា ខ្សែភាពយន្ត កាសែ្សតវីដេអូ ឡាស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី ស៊ីឌីរ៉ូម ។

**ជំពូកទី ២**

**និតិនិយមន័យ**

មាត្រា ៣ .-

និយមន័យទាំងឡាយចែងក្នុងអនុក្រឹត្យនេះ មានតម្លៃសំរាប់ប្រើប្រាស់តែក្នុងអនុក្រឹត្យនេះប៉ុណ្ណោះ

មាត្រា ៤ .-

ស្នាដៃគឺជាការបង្កើតថ្មីទាំងអស់របស់បញ្ញា ។

មាត្រា ៥ .-

ស្នាដៃភាពយន្តគឺជា ខ្លឹមសារ រូបភាព សំឡេងដែលស្ថិតក្នុង :

ក :- ខ្សែភាពយន្តរឿង : ខ្នាតវែង ខ្លី ភាគ

ខ :- ខ្សែភាពយន្តឯកសារស្តីពី រមណីយដ្ឋានវប្បធម៌ : ខ្នាតវែង ខ្លី

គ :- ខ្សែភាពយន្តឯកសារពាក់ព័ន្ធដល់ប្រពៃណីជាតិ : ខ្នាតវែង ខ្លី

ឃ :- ខ្សែភាពយន្តគំនូរជីវចល

**មាត្រា ៦ .-**

ខ្សែភាពយន្តខ្នាតវែង ជាខ្សែភាពយន្តដែលមានរយៈពេលបញ្ចាំងចាប់ពី ៦០នាទីឡើងទៅ ។

**មាត្រា ៧ .-**

ខ្សែភាពយន្តខ្នាតខ្លី ជាខ្សែភាពយន្តដែលមានរយៈពេលបញ្ចាំងតិចជាង ៦០នាទី ។

**មាត្រា ៨ .-**

ខ្សែភាពយន្តភាគ ជាខ្សែភាពយន្តដែលមានដំណើររឿងចែកជាវគ្គខ្លីៗ ។

**មាត្រា ៩ .-**

ស្នាដៃវីដេអូគឺជា : វីដេអូរឿងវែង ខ្លី ភាគ វីដេអូខារ៉ាអូខេ វីដេអូចម្រៀងកាយវិការ វីដេអូជំនួរ ជីវចល វីដេអូឯកសារស្ដីពីរមណីយដ្ឋានវប្បធម៌ និងវីដេអូឯកសារដែលពាក់ព័ន្ធ ដល់ប្រពៃណីជាតិ ។

**មាត្រា ១០ .-**

- **ទីដេអូ "គុណនាម"** សំដៅបច្ចេកទេសដែលពាក់ព័ន្ធដល់ការបង្កើត ការថតបញ្ចូល ប្រព្រឹត្តកម្ម ការរក្សាទុក ការបញ្ជូនរូបភាព ឬ សញ្ញាប្រភេទទូរទស្សន៍ ។
- **ទីដេអូ "នាម"** ១ : សំដៅបច្ចេកទេសវីដេអូទាំងឡាយ ។
  ២ : ស្នាដៃទាំងឡាយដែលថតជាវីដេអូ ។

**មាត្រា ១១ .-**

ខារ៉ាអូខេជាពាក្យជប៉ុន ។ " ខារ៉ា = ទំនេរ អូខេ = តន្ត្រី " វីដេអូខារ៉ាអូខេ គឺជាវីដេអូតន្ត្រីសំរាប់ អ្នកទស្សនាអាចច្រៀងតាមបាន ។

## ជំពូកទី ៣
## អំពីអាជ្ញាប័ណ្ណធ្វើផលិតកម្ម ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

**មាត្រា ១២ .-**

ក្រុមហ៊ុនផលិតកម្ម ឬ រូបវន្តបុគ្គលដែលមានបំណងធ្វើផលិតកម្មភាពយន្ត ឬ ផលិតកម្មវីដេអូ ក្នុងប្រទេស ដើម្បីផលិតចេញជាស្នាដៃភាពយន្ត និងស្នាដៃវីដេអូ សំរាប់ធ្វើអាជីវកម្មផ្សព្វផ្សាយ ទាំងក្នុង និងក្រៅប្រទេស ត្រូវសុំអាជ្ញាប័ណ្ណពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោយពីការចុះបញ្ជីពាណិជ្ជកម្មនៅ ក្រសួងពាណិជ្ជកម្មរួច ។

**មាត្រា ១៣ .-**

មុននឹងអនុញ្ញាតអោយធ្វើអាជីវកម្មតាមគ្រប់មធ្យោបាយ ក្រុមហ៊ុនផលិតកម្មទាំងអស់ ទាំងក្នុងស្រុក ទាំងបរទេស ដែលមានបំណងផលិតស្នាដៃភាពយន្ត និងស្នាដៃវីដេអូ ត្រូវយកអត្ថបទរឿងពិស្ដារជា អក្សរសិល្ប៍ភាសាជាតិ មានពាក្យសន្ទនា ទំនុកច្រៀង ឬអត្ថបទសង្ខេបឯកសារទៅដាក់ជូនក្រសួង វប្បធម៌ និងវិចិត្រសិល្បៈពិនិត្យនិងយល់ព្រមជាមុនសិន ដើម្បីផ្ដល់លិខិតអនុញ្ញាតអោយផលិតក្នុងរយៈ ពេល១៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីដាក់ពាក្យស្នើសុំ បើហួសកំណត់នេះ ត្រូវចាត់ទុកថាបានយល់ព្រម ។

ចំពោះក្រុមហ៊ុនបរទេសត្រូវភ្ជាប់ជាមួយផងដែរនូវច្បាប់បង្កើតក្រុមហ៊ុនរបស់ខ្លួន ។

មាត្រា ១៤ .-

កិច្ចសហការជាមួយក្រុមហ៊ុនផលិតកម្មបរទេស ជនបរទេស ឬពលរដ្ឋកម្ពុជា ដែលរស់នៅបរទេស មានបំណងមកផលិតស្នាដៃភាពយន្ត និងស្នាដៃវីដេអូ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាភារកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងព័ត៌មាន ។

មាត្រា ១៥ .-

ការចេញអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា១២ ការពិនិត្យ និងផ្តល់ការយល់ព្រមក្នុងមាត្រា១៣ និងការអនុញ្ញាតអោយចូលមកថតខ្សែភាពយន្ត ឬ វីដេអូក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់កំរៃអាជ្ញាប័ណ្ណ និង កំរៃរដ្ឋបាលជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលកំណត់ដោយប្រកាសរួមរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## អំពីការធ្វើអាជីវកម្ម ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា ១៦ .-

ការប្រកបមុខរបរធ្វើអាជីវកម្មស្នាដៃភាពយន្ត និងស្នាដៃវីដេអូរួមមាន ៖ ការបើកអាជីវកម្មនាំចេញ-នាំចូល ចែកបញ្ចាំង ថតចម្លង បញ្ចូលសំឡេង កាត់ត ជាឡើងភាពយន្ត ឬវីដេអូសំរាប់ធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ១៧ .-

ការបើករោងបញ្ចាំងភាពយន្ត ឬរោងបញ្ចាំងវីដេអូត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ៖

ក-អំពីបទដ្ឋានសន្តិសុខ ៖ រៀបចំលក្ខណៈអគ្គីភ័យ និងការជ្រួលច្របល់ផ្សេងៗសមស្របតាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

ខ-អំពីបទដ្ឋានបច្ចេកទេស ៖ ទំហំផ្ទាំងសំពត់ស ការរៀបចំកន្លែងសំរាប់ទស្សនិកជន ការរៀបចំបន្ទប់បញ្ចាំង សមស្របតាមការកំណត់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## ជំពូកទី ៥

## អំពីការពិនិត្យខ្លឹមសារ និងផ្តល់ទិដ្ឋាការស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា ១៨ .-

ការពិនិត្យខ្លឹមសារ នៃស្នាដៃភាពយន្ត និងស្នាដៃវីដេអូ ជាសមត្ថកិច្ច របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ក្នុងករណីចាំបាច់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមពិនិត្យ និងសំរេច ។

មាត្រា ១៩ .-

ការផ្ដល់ទិដ្ឋាការអោយស្នាដៃភាពយន្ត ឬវីដេអូ សំរាប់យកទៅធ្វើអាជីកម្ម ចាក់បញ្ចាំង ឬផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ ជាភារកិច្ចរបស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ២០ .-

ស្នាដៃភាពយន្ត និងស្នាដៃវីដេអូតាមទម្រង់ដូចមានចែងក្នុងមាត្រា២ ខាងលើ មុននឹងយកទៅធ្វើអាជីវកម្មជួល លក់ ចាក់បញ្ចាំង ផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ ឬនាំចេញទៅក្រៅប្រទេស ត្រូវមានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

លក្ខខណ្ឌនៃការសុំទិដ្ឋាការអនុញ្ញាតសំរាប់ ស្នាដៃភាពយន្ត និងស្នាដៃវីដេអូ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## ជំពូកទី ៦

## អំពីការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសក្នុងសកម្មភាព ផលិត ធ្វើអាជីវកម្ម និង ផ្សព្វផ្សាយស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា ២១ .-

ការធ្វើអាជីវកម្ម ជួល ឬលក់ កាសែ្សតវីដេអូ ឡាស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី និងការធ្វើអាជីវកម្មខារ៉ាអូខេ ត្រូវមានការត្រួតពិនិត្យពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ២២ .-

ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសក្នុងសកម្មភាពធ្វើអាជីវកម្ម និងផ្សព្វផ្សាយស្នាដៃភាពយន្ត ឬស្នាដៃវីដេអូ ដូចមានចែងក្នុងមាត្រា១២.១៣ និង១៤ រួមទាំងការប្រកបមុខរបរដូចមានចែង ក្នុងមាត្រា ១៦ និង១៧ ជាសមត្ថកិច្ច របស់ក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ ។

ក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ ត្រូវសុំបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសហការត្រួតពិនិត្យ ឬបង្ក្រាប ដែលកំណត់ដោយសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ២៣ .-

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង និងការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ខណ្ឌ ស្រុក នីមួយៗ មានភារកិច្ចត្រួតពិនិត្យ និង បង្ក្រាបសកម្មភាពផលិត ធ្វើអាជីវកម្ម និងផ្សព្វផ្សាយស្នាដៃភាពយន្ត និងស្នាដៃវីដេអូ ដោយសហការជាមួយអាជ្ញាធរដែនដី ខេត្ត ក្រុង និង ខណ្ឌ ស្រុករបស់ខ្លួន។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

មាត្រា ២៤ .-

ត្រូវផ្អាកសកម្មភាព និងពិន័យជាប្រាក់ពី ហុកសិបម៉ឺនរៀល (៦០.០០០រ០០) ទៅ ពីរសែនរៀល (២០០.០០០រ០០) ចំពោះជនណាដែលប្រព្រឹត្តិល្មើសនឹងមាត្រា ១២.១៣.១៤.១៦. និង ១៧ នៃ អនុក្រឹត្យនេះ ។

**មាត្រា ២៥ .-**

ជនណាដែលយកស្លាដែភាពយន្ត និងស្លាដែវីដេអូគ្មានទិដ្ឋាការអនុញ្ញាតពីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ទៅដាក់តាំង ជួល លក់ ត្រូវពិន័យជាប្រាក់តាម លក្ខខណ្ឌដូចខាងក្រោម :

១-ពិន័យជាប្រាក់ពីប្រាំពីរពាន់ប្រាំរយរៀល (៧.៥០០៛០០) ទៅប្រាំមួយម៉ឺនរៀល(៦០.០០០៛០០) សំរាប់កាសែ្សតវីដេអូមួយដុំ ឡាស៊េរឌីស ស៊ីឌីវីដេអូ ឌីវីឌី និង ស៊ីឌីរ៉ូមមួយ ។

២-ពិន័យជាប្រាក់ពី ពីរសែនរៀល (២០០.០០០៛០០) ទៅពីរលានរៀល (២.០០០.០០០៛០០) ចំពោះខ្សែភាពយន្តខ្នាតវែង មួយរឿង ។

**មាត្រា ២៦ .-**

ជនណាយកស្លាដែភាពយន្ត និងស្លាដែវីដេអូគ្មានទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នាំចេញទៅក្រៅប្រទេស ដើម្បីធ្វើអាជីវកម្ម ត្រូវដកហូត និងពិន័យជាប្រាក់ ពី ពីរសែនរៀល (២០០.០០០៛០០) ទៅពីរលានរៀល (២.០០០.០០០៛០០) សំរាប់កាសែ្សតវីដេអូ មួយដុំ ឡាស៊េរឌីស ស៊ីឌីវីដេអូ ឌីវីឌី និង ស៊ីឌីរ៉ូមមួយ ឬខ្សែភាពយន្តខ្នាតវែងមួយរឿង លើកលែងតែភាពយន្ត និងវីដេអូមានលក្ខណៈជាគ្រួសារដែលមិនតម្រូវអោយមានទិដ្ឋាការពីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ឡើយ ។

**មាត្រា ២៧ .-**

ជនណាយកស្លាដែភាពយន្ត និងស្លាដែវីដេអូគ្មានទិដ្ឋាការទៅផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ ត្រូវពិន័យជាប្រាក់ ពី ប្រាំមួយម៉ឺនរៀល (៦០.០០០៛០០) ទៅពីរសែនរៀល (២.០០.០០០៛០០) ។

**មាត្រា ២៨ .-**

ជនណាបញ្ចាំង កាត់ត ដំឡើងរូបភាព ថតចម្លង ថតបញ្ចូលសម្លេង ជួល លក់ និងចែកចាយ សំរាប់ធ្វើអាជីវកម្មនូវផលិតផលភាពយន្ត ឬវីដេអូដែលមានលក្ខណៈរូបភាពអាសអាភាស ត្រូវពិន័យជាប្រាក់ ពី ពីរសែនរៀល (២០០.០០០៛០០) ទៅពីរលានរៀល (២.០០០.០០០៛០០) ហើយដកហូតទាំងឧបករណ៍ សំភារៈភាពយន្ត ឬវីដេអូ ក្នុងការធ្វើអាជីវកម្មនោះ ។ ដោយខ្សែខ្សែភាពយន្ត ឬកាសែ្សតវីដេអូ ឡាស៊េរឌីស ស៊ីឌីវីដេអូ ឌីវីឌី និង ស៊ីឌីរ៉ូម ត្រូវបំផ្លាញចោល ។

**មាត្រា ២៩ .-**

ការី និងសហការី ក្នុងការផលិតស្លាដែភាពយន្ត ឬវីដេអូគ្មានអាសអាភាស ត្រូវដកហូតឧបករណ៍ សំភារៈ ហើយកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ៣០ .-**

ជនណាធ្វើការក្លែងបន្លំ លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ទិដ្ឋាការ បន្ថែមរូបភាព បញ្ចូលពាក្យសន្ទនា ឬ បញ្ចូលបទអត្ថាធិប្បាយទៅក្នុង ស្លាដែភាពយន្ត ឬ វីដេអូថ្មីយពីច្បាប់ដើម ដែលក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ បានអនុញ្ញាតជាផ្លូវការរួចហើយ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា ៣១ .-

ជនណាយកផលិតផលភាពយន្ត ឬវីដេអូរបស់ក្រុមហ៊ុនណាមួយ ដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានផ្តល់ទិដ្ឋាការរួចហើយ ទៅលួចចម្លងដើម្បីធ្វើអាជីវកម្ម ចាក់បញ្ចាំង ឬ ផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់មធ្យោបាយ ធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍អ្នកដទៃ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា ៣២ .-

ការពិន័យជាប្រាក់ដូចមានចែងក្នុងមាត្រា ២៤.២៥.២៦.២៧ និង២៨ នៃអនុក្រឹត្យនេះ នឹងត្រូវបង្កើនទ្វេឡើង ឬបិទលប់អោយធ្វើអាជីវកម្មជាស្ថាពរ កាលណាជនល្មើសនៅតែប្រព្រឹត្តិល្មើសបន្តទៀត ។

មាត្រា ៣៣ .-

មន្ត្រីរាជការទាំងឡាយ ដែលមានភារកិច្ចពិនិត្យខ្សែភាពយន្ត ឬវីដេអូ និងត្រួតពិនិត្យឬបង្ក្រាបបទល្មើសភាពយន្ត វីដេអូ មានការឃុបឃិត ឬប្រព្រឹត្តិរំលោភភារកិច្ចរបស់ខ្លួនផ្ទុយពីបញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទោសតាមបទប្បញ្ញត្តិច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ។

មាត្រា ៣៤ .-

ប្រាក់ពន្ធអាជ្ញាប័ណ្ណ និងកំរៃរដ្ឋបាល ដូចមានចែងក្នុងមាត្រា ១២ និង ១៣ ត្រូវបង់ចូលថវិការដ្ឋទាំងអស់ ។

ប្រាក់ពិន័យដូចមានចែងក្នុងមាត្រា ២៤.២៥.២៦.២៧ និង២៨ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានទទួលចំណែក ៤០% សំរាប់ប្រើប្រាស់ជាផលប្រយោជន៍ ដល់វិស័យសិល្បៈ និងវប្បធម៌ ។

ខ្ទង់ប្រាក់ចំណូលពីការផាកពិន័យទាំងអស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តកាតព្វកិច្ចបង់ចូលថវិការដ្ឋ តាមមាត្រា ១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាមុនសិន ។ រីឯចំណែក ៤០% ត្រូវលើកសំណើសុំចំណាយវិញ ដោយផ្អែកលើលិខិតបង់ប្រាក់ ឬ ប័ណ្ណបង្វែរគណនី ជាសក្ខីភាពថាពិតជាបានបង់ចូលថវិការដ្ឋរួចហើយ ។

## ជំពូក ទី ៨

## អន្តរប្បញ្ញត្តិ

មាត្រា ៣៥ .-

គ្រប់ក្រុមហ៊ុននាំចេញ នាំចូល និង អាជីវករទាំងអស់ ដែលយកស្នាដៃភាពយន្ត ឬស្នាដៃវីដេអូគ្មានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទៅជួល លក់ ចាក់បញ្ចាំង ផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់មធ្យោបាយ ត្រូវរួតរះយកស្នាដៃភាពយន្ត ឬស្នាដៃវីដេអូទាំងនោះ ទៅសុំទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០០១ ។

## ជំពូក ទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ៣៦ .-

អនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យភាពយន្ត និងវីដេអូរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីរដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ព្រះហស្តលេខា

**នរោត្តម បុប្ផាទេវី**

***

## អនុក្រឹត្យ លេខ ៦៥ អនក្រ.បក

## ស្តីពី

## ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំ ឆ្នាំ ២០០១

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ-អន្តរជាតិ លេខ ១៦១/២០០០/គ.ប.ជ.អ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០

## សំរេច

**មាត្រា ១ .-** អនុញ្ញាតិអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា ទាំងអស់ បានឈប់សំរាកការងារប្រចាំឆ្នាំ ២០០១ តាមប្រតិទិន ដូចខាងក្រោម :

| | | |
|---|---|---|
| -ថ្ងៃទី០១ មករា | - ទិវាចូលឆ្នាំសកល | ឈប់ ០១ថ្ងៃ |
| -ថ្ងៃទី០៧ មករា | - ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | ឈប់ ០១ថ្ងៃ |
| -ថ្ងៃទី០៨ មីនា | - ទិវានារីអន្តរជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១៣-១៤-១៥-១៦ មេសា | - ទិវាចូលឆ្នាំប្រពៃណីជាតិ (១) | ឈប់០៤ថ្ងៃ |
| -ថ្ងៃទី០១ ឧសភា | - ទិវាពលកម្មអន្តរជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី០៧ ឧសភា | - បុណ្យវិសាខបូជា | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១១ ឧសភា | - ពិធីបុណ្យច្រត់ព្រះនង្គ័ល | ឈប់០១ថ្ងៃ |
| -ថ្ងៃទី០១ មិថុនា | - ទិវាកុមារអន្តរជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១៨ មិថុនា | - ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១៦-១៧-១៨ កញ្ញា | - បុណ្យភ្ជុំបិណ្ឌ | ឈប់០៣ថ្ងៃ |
| -ថ្ងៃទី២៤ កញ្ញា | - ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី២៣ តុលា | - ទិវាសន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស | ឈប់០១ថ្ងៃ |
| -ថ្ងៃទី៣០-៣១ តុលា និង ០១ វិច្ឆិកា | - ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ និងពិធីបុណ្យ អុំទូក សំពះព្រះខែ អកអំបុក បណ្តែតប្រទីប (២) | ឈប់០៣ថ្ងៃ |
| -ថ្ងៃទី០៩ វិច្ឆិកា | - ទិវាបុណ្យឯករាជជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១០ ធ្នូ | - ទិវាសិទ្ធិមនុស្ស អន្តរជាតិ | ឈប់០១ថ្ងៃ |

មាត្រា ២ .- ពេលវេលាឈប់សំរាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានអោយឈប់សំរាកចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវបានអនុញ្ញាតិអោយឈប់បន្ថែមជាជំនួស គឺឈប់តែចំនួន០១ថ្ងៃប៉ុណ្ណោះ ។

មាត្រា ៣ .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បញ្ជាក់ (១) - ទិវាបុណ្យចូលឆ្នាំថ្មី មានរយៈពេល ៤ថ្ងៃ ដោយឆ្នាំនេះ មានវ័នប័តពីរ

(២) - ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ស្របជាមួយពិធីបុណ្យអុំទូក សំពះព្រះខែ អកអំបុក បណ្តែតប្រទីប ។

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យ លេខ ៣៣៨ អនក្រ.តត**

**ស្តីពី**

**ការផ្ទេរក្របខណ្ឌមន្ត្រីរាជការ**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ .- ត្រូវបានផ្ទេរលោក កៅ ខុនតារា ពីក្រសួងពាណិជ្ជកម្ម អោយទៅបំរើការងារនៅក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយបានសម្រេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៣៣៩ អនក្រ.តត

## ស្តីពី

## ការផ្ទេរភារកិច្ច របស់មន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

មាត្រា ១ .- ផ្ទេរភារកិច្ច លោក អៀវ លីហេង ប្រធាននាយកដ្ឋានស្ថិតិនៃក្រសួងផែនការ អោយទៅបំរើការងារនៅអគ្គាធិការដ្ឋាននៃក្រសួងផែនការវិញ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងលោក អៀវ លីហេង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

អនុក្រឹត្យ លេខ ៣៨០ អនក្រ.តត
ស្តីពី
ការជូនមេដាយស្ថាបនាជាតិ

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោកវរសេនីយ៍ទោ សុខ វិជ្ជល មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារវត្តអូរព្រះ ក្នុងសង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ អស់ទឹកប្រាក់ចំនួន១២.០០០ ដុល្លារអាមេរិក

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

អនុក្រឹត្យ លេខ ៣៨១ អនក្រ.តត
ស្តីពី
ការជូនមេដាយស្ថាបនាជាតិ

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ ជូនសប្បុរសជន ០៩រូប ដែលបានបរិច្ចាគធនធានជួយឧបត្ថម្ភជាថ្នាំពេទ្យ និងសំភារៈផ្សេងៗ ដល់កងទ័ពជើងគោក ដូចមានរាយនាមនិងចំនួនទឹកប្រាក់ខាងក្រោម :

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកវរសេនីយ៍ឯក | អ៊ុក គោសា | ទឹកប្រាក់ | ១២.000USD |
| ២-លោក | TSAI SHI PEI | ទឹកប្រាក់ | ១៣.២00USD |
| ៣-លោក | SUSAN HUANG | ទឹកប្រាក់ | ១២.000USD |
| ៤-លោក | JANE MIN CHENG | ទឹកប្រាក់ | ១១.000USD |
| ៥-លោក | YAO TE LIM | ទឹកប្រាក់ | ១0.000USD |

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

| | | | |
|---|---|---|---|
| ១-លោក | PAN TING HSIUNG | ទឹកប្រាក់ | ៩.000USD |
| ២-លោក | CHENG WANG CHENG | ទឹកប្រាក់ | ៨.000USD |
| ៣-លោក | YINH TYAN SHI EH | ទឹកប្រាក់ | ៨.000USD |
| ៤-លោក | HSIN HUA LIM | ទឹកប្រាក់ | ៧.៥00USD |

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

ហេត្តបណ្ឌិតនិងគ្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៣៨២ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

## សម្រេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ហេង សម្បត្តិ** ហៅ **មួង ទ្រី** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជាទឹកប្រាក់ចំនួន ១១.៥០០ ដុល្លារអាមេរិក សំរាប់ចូលរួមកសាងឧបដ្ឋានសាលា អាងទឹក ជីកស្រះទឹក និងចាក់ដីបំពេញទីធ្លា ក្នុងវត្តភ្នំខ្លែង ឃុំ ព្រៃស្លឹក ស្រុកត្រាំង ខេត្តតាកែវ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ៣៨៣ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ព្រះចៅអធិការ និងគណៈកម្មការ អាចារ្យវត្ត ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគធនធាន និងកំលាំងកាយចិត្ត ចូលរួមកសាងសមិទ្ធផលផ្សេងៗ ដូចជា : សាលារៀន ព្រះវិហារ ផ្លូវលំ ស្រះទឹក កុដិ ។ល។ នៅក្នុងវត្ត "បារាយណ៍វិហារពីរ" ឃុំព្រៃស្លឹក ស្រុកត្រាំង ខេត្តតាកែវ ចំណាយអស់ថវិកាសរុបចំនួន : ២២៨.០៨០ ដុល្លារអាមេរិក ដូចមានរាយព្រះនាម និងនាមខាងក្រោម :

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឯកឧត្ដម ឡៅ សេង | អគ្គទេសាភិបាលធនាគារជាតិ | បរិច្ចាគប្រាក់ | ១៨.០៥៨USD |
| ២-លោក ថេ ថន | នៅសហរដ្ឋអាមេរិក | បរិច្ចាគប្រាក់ | ១៤.៧៥០USD |
| ៣-ព្រះគ្រូ ហម សារឿន | ចៅអធិការវត្តបារាយណ៍វិហារពីរ | | |

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | |
|---|---|
| ១-លោកតា នឹម យុត | ប្រធានគណៈកម្មការសាងសង់ |
| ២-លោក ម៉ុំ សារឹទ្ធី | នាយកសាលាបឋមសិក្សា វត្តបារាយណ៍វិហារពីរ |
| ៣-លោកតា អ៊ុំ សុន | ប្រធានអាចារ្យប្រចាំវត្ត |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥៨ សសរ

ស្តីពី

ការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមជំនួបកំពូលសហស្សវត្សរ៍ នៃអង្គការសហប្រជាជាតិ ចាប់ពីថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តី សំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥៩ សសរ

ស្តីពី ការបង្កើតគណៈកម្មការដើម្បីទប់ស្កាត់ទឹកជំនន់

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់ របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការមួយដើម្បីទប់ស្កាត់ទឹកជំនន់ជុំវិញរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២-ឯកឧត្តម ស៊ុំ ម៉ានិត | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម ច័ន្ទ តុងអ៊ីវ | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-ឯកឧត្តម ចាយ សាំងយុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦-ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧-ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨-ឯកឧត្តម ម៉ប់ សារិន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ៩-ឯកឧត្តម ឧ.សេនីយ៍ឯក សូរ ផន | អគ្គនាយករងទី១នគរបាលជាតិ | សមាជិក |
| ១០-ឯកឧត្តម ពៅ សាមី | អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | លេខាធិការ |

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ច ៖

-លើកផែនការ និងរៀបចំកំលាំងប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និងមន្ត្រីរាជការតាមក្រសួងស្ថាប័ន ដើម្បីលើកទំនប់ទប់ស្កាត់ទឹកជំនន់ ដែលកំពុងគំរាមកំហែងមកលើរាជធានីភ្នំពេញ

-ត្រៀមជួយជំលៀសប្រជាពលរដ្ឋចេញពីកន្លែងដែលទឹកជន់លិច

-ត្រៀមស្បៀង ថ្នាំពេទ្យ និងសំភារៈចាំបាច់នានា សំរាប់ឧបត្ថម្ភជនរងគ្រោះ ។

ប្រធានគណៈកម្មការត្រូវអញ្ជើញសមាជិកប្រជុំ និងចាត់ចែងការងារជាបន្ទាន់ ដើម្បីត្រៀមដោះស្រាយអោយទាន់សភាពការណ៍ ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ និងសមាសភាពគណៈកម្មការ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី ស្តីទី
ហត្ថលេខានិងត្រា
ស ខេង

★★★

## ៣- សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

### សារាចរ លេខ ០២ សរ
### ស្តីពី
### ការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៧៨ យាងចូល ៧៩ ព្រះវស្សា បុណ្យខួបអនុស្សាវរីយ៍លើកទី ៤៧ នៃទិវាបុណ្យឯករាជជាតិ ៩ វិច្ឆិកា និងបុណ្យ អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

* * *

- ពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ ក្នុងគម្រប់ព្រះជន្ម ៧៨ យាងចូល ៧៩ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ថ្ងៃ ចាប់ពីថ្ងៃទី៣០-៣១ តុលា ដល់ថ្ងៃ ០១ វិច្ឆិកា ២០០០ ខាងមុខនេះ ដើម្បីសំដែងកត្តញ្ញូតាធម៌ចំពោះព្រះមហាករុណាធិគុណ ថ្វាយព្រះពរសព្ទសាធុការ និងថ្វាយមហាកុសលចំពោះ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខមាលភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់របស់ ប្រជារាស្ត្រខ្មែរយូរអង្វែងតរៀងទៅ ។
- ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៧ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី០៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដើម្បីសំដែងមនោសញ្ចេតនាអបអរសាទរ រំលឹកទិវាជាប្រវត្តិសាស្ត្រ ដែលកំលាំងមហាសាមគ្គីជាតិទាំងមូលដណ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំង នាឆ្នាំ ១៩៥៣ នូវឯករាជ្យជាតិដ៏ពិតប្រាកដ ក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លា នៃ ព្រះករុណា ព្រះបាទសម្តេច‌ព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ។
- ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ថ្ងៃ គឺថ្ងៃ ១៤-១៥កើត និងថ្ងៃ ១រោច ខែកត្តិក ត្រូវនឹងថ្ងៃទី ១០-១១-១២ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដើម្បីបើកឱកាសជូន

ប្រជារាស្ត្រសប្បាយរីករាយ ចូលរួមថែរក្សានូវប្រពៃណីរបស់ជាតិ ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធនៃកំលាំងភាគម្គីកងទ័ពជើងទឹករបស់យើង ក្នុងបុព្វហេតុការពារមាតុភូមិ និងសំដែងនូវមនោសញ្ចេតនា ប្រកបដោយកតញ្ញូតាធម៌ ចំពោះមហាករុណាទិគុណនៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុសក្តិសិទ្ធិ ដែលបានគាំពារ និងជួយឧបត្ថម្ភអោយវិស័យកសិកម្មជាតិ មានការរីកចំរើនរុងរឿង ព្រមទាំងជាឱកាសបួងសួងសុំអោយបារមី នៃព្រះពុទ្ធជាម្ចាស់ និងវត្ថុសក្តិសិទ្ធិទាំងអស់ បន្តជួយឧបត្ថម្ភវិស័យកសិកម្ម នារដូវខាងមុខអោយទទួលបានជោគជ័យ និងទិន្នផលខ្ពស់ជាងថែមទៀត ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យទាំងបីនេះអោយបានសមរម្យ សក្តិសមទៅនឹងព្រះមហាករុណាទិគុណ និងព្រះរាជវិបុលធម៌ដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង សក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅដូចបានបញ្ជាក់ខាងលើនេះ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវគោលការណ៍ណែនាំអនុវត្តដូចតទៅ ៖

**១-ពិធីបុណ្យចំរើនព្រះជន្មវស្សាព្រះករុណាជាម្ចាស់ជីវិតលើត្បូង :**

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ខេត្ត-ក្រុង ត្រូវរៀបចំតាំងព្រះឆាយាលក្ខណ៍ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង តុបតែងលំអ រចនាដោយភ្លើងពណ៌ ពាក្យស្លោកថ្វាយព្រះពរ និងសារថ្វាយព្រះពរ ។

-ចំពោះព្រះរាជពិធីនៅក្នុងព្រះបរមរាជវាំង អាស្រ័យដោយក្រសួងព្រះបរមរាជវាំងចាត់តាំងព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជាម្ចាស់ជីវិតលើត្បូង អោយបានសមស្របតាមប្រពៃណីជាតិ និងប្រពៃណីសាសនា ។

-គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាជាម្ចាស់ជីវិតលើត្បូងក្នុងក្របខណ្ឌខេត្ត-ក្រុងរបស់ខ្លួន តាមលទ្ធភាពជាក់ស្តែងដោយមានការរៀបចំសារថ្វាយព្រះពរ ។

**២-អំពីពិធីបុណ្យឯករាជជាតិ :**

-ត្រូវចាត់តាំងរៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៤៧ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ក្នុងកិរិតរូបភាពមួយដ៏មហោឡារិក សក្តិសមទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានការចាត់តាំងមិទ្ទិញមហាជនមួយនៅបរិវេណវិមានឯករាជ្យ មានថ្នាក់ដឹកនាំជាតិ-មន្ត្រីរាជការ-សិស្សានុសិស្ស និងភ្ញៀវអន្តរជាតិ ចូលរួមអោយបានច្រើនកុះករ និងមានចាត់តាំងពិធីដុតទៀនជ័យ ដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ និងពន្លត់ទៀនជ័យនៅវិមានឯករាជ្យ ព្រមទាំងមានបង្ហោះប៉េងប៉ោង លែងព្រាបជានិមិត្តរូប នៃការសុំសុខសន្តិភាពផង ។

ខេត្ត-ក្រុង ត្រូវចាត់តាំងពិធីមិទ្ទិញមហាជន និង ពិធីគោរពវិញ្ញាណក្ខន្ធនៅតាមទីកន្លែង ដ៏សមគួរតាមការជាក់ស្តែងរបស់ខេត្ត-ក្រុង នីមួយៗ ។

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវរៀបចំកម្មវិធីសំរាប់ថ្នាក់ដឹកនាំក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចុះសួរសុខទុក្ខយុទ្ធជនរបួស មានជម្ងឺ កំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យយុទ្ធជនពិការនៅតាមមណ្ឌលយុទ្ធជនពិការ កុមារកំព្រា នៅតាមមណ្ឌលកុមារកំព្រា ដោយមាននាំអំណោយ

ជួយឧបត្ថម្ភ និងបំផុសអោយគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចងបដា ពាក្យស្លោក ដោតទង់ជាតិ ទង់ក្ងោក និងតុបតែង ពាក់អំពូលភ្លើងពណ៌អោយបានឧឡារិក ។

**៣-អំពីពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក :**

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងពាក់ព័ន្ធ និងខេត្ត-ក្រុង ចាត់តាំងរៀបចំពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាប នៅវេទិកាអុំទូក មុខព្រះបរមរាជវាំង ក្នុងរយៈកាល ៣ថ្ងៃ តាមប្រពៃណីជាតិ ប្រពៃណីសាសនា ដោយមានចាត់តាំងក្រសួងមួយចំនួន រចនាតុបតែងជាប្រទីប មានអុជកាំជ្រួចភ្លឺទៀន មានតាំងភ្លើងពណ៌ ស្រស់ស្អាតពេលយប់ នៅរាជធានីភ្នំពេញ។

-ត្រូវមានផែនការណែនាំលំអិតជាក់ស្តែង ស្តីពីលក្ខខណ្ឌទាំងឡាយនៃការជ្រើសរើសទូក ង ដែលត្រូវចូលរួមប្រណាំង ដោយត្រូវកំណត់ទូកអុំ-ទូកចែវ អោយបានច្បាស់លាស់ និងត្រូវធ្វើសេចក្តីអំពាវនាវសប្បុរសជន បណ្តាក្រុមហ៊ុនឯកជន អោយជួយឧបត្ថម្ភ ជាសំភារៈ ថវិកា សំរាប់ជូនរង្វាន់ដល់កីឡាករអុំទូក ។

-ត្រូវបូកសរុបតំរោងថវិកាចំណាយលំអិត ដែលក្រសួងពាក់ព័ន្ធបានលើកឡើងក្នុងស្មារតីសន្សំសំចៃ ថ្លៃប្រឹងខ្ពស់ ផ្ញើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និង សំរេច ។

-ខេត្ត-ក្រុង ដែលមានទូក ង ចូលរួមប្រណាំង ត្រូវធ្វើការសាកល្បងហ្វឹកហាត់ចម្រាញ់ជ្រើសរើសទូកដែលមានចំណាត់ថ្នាក់ជាទូកលឿនរបស់ខេត្ត-ក្រុង ក្នុងចំនួនសមស្របសំរាប់ចូលរួមប្រណាំងនៅ រាជធានីភ្នំពេញ ។

-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវចាត់តាំងរៀបចំកម្មវិធីសិល្បៈ ‛ធ្វើការណែនាំដល់មន្ត្រីវប្បធម៌ខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈបុរាណ សម័យ និងចំរៀង បុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្ត នៅតាមទីសាធារណៈ អបអរសាទរក្នុងពិធីបុណ្យទាំងបីខាងលើ ។

-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសំភារៈ និងថវិកាសំរាប់បំរើការរៀបចំពិធីបុណ្យទាំងបីខាងលើ អោយបានសមស្រប និងទាន់ពេលវេលា ។

-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវត្រៀមលក្ខណៈចាត់តាំងការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ តាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព និងសេចក្តីសប្បាយរីករាយជូនប្រជាពលរដ្ឋយើង ។

ទទួលបានសារាចរនេះ សូមឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ចាត់តាំងអនុវត្តអោយបានសំរេចលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរ ហើយធ្វើរបាយការណ៍បូកសរុបជូនរាជរដ្ឋាភិបាល ។

**នាយករដ្ឋមន្ត្រី**

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# ពាក្យស្លោកសំរាប់ប្រើប្រាស់
# ក្នុងពិធីបុណ្យចំរើនព្រះជន្ម ព្រះមហាក្សត្រ
# បុណ្យឯករាជ្យជាតិ និង បុណ្យអុំទូក ឆ្នាំ ២០០០

* * *

១- សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា មានព្រះសុខមាលភាពបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២- សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៣- ជយោ ! សម្តេចឪ និង សម្តេចម៉ែ

៤- សូមថ្វាយព្រះពរសម្តេចឪ ក្នុងព្រះរាជពិធីបុណ្យចំរើនព្រះជន្មគម្រប់ ៧៨ យាងចូល ៧៩ ព្រះវស្សា ជាទីគោរពសក្ការៈ ។

៥- អបអរសាទរយ៉ាងក្លៀវក្លា ខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាបុណ្យឯករាជជាតិ ៩ វិច្ឆិកា "០៩-១១-៥៣ - ០៩-១១-២០០០"

៦- ចងចាំជានិច្ច នូវព្រះរាជបូជនីយកិច្ចទាមទារឯករាជជាតិដ៏ឧត្តុង្គឧត្តមរបស់ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

៧- ជយោ ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា

៨- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៩- ជយោ ! ព្រះរាជាណាចក្រកម្ពុជា

១០-ជាតិ សាសនា ព្រះមហាក្សត្រ

១១-អបអរសាទរ ទិវាបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

១២-អបអរសាទរ លទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

១៣-ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍

១៤-ជយោ ! សម្តេចព្រះបិតាឯករាជជាតិ

១៥-ជយោ ! សម្តេចព្រះបិតាសន្តិភាព ផ្សះផ្សាជាតិ និង បង្រួបបង្រួមជាតិ

១៦-ស្វាគមន៍ឆ្នាំ ២០០០ និងសហស្សវត្សថ្មី

# III- ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីអប់រំយុវជន និងកីឡា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០០

**ប្រកាស លេខ ៩៦៣ អយក.ប្រក**

**ស្ដីពី**

**ការបើកអនុវិទ្យាល័យ ញ្ញៅ ស្ថិតនៅក្នុងឃុំ ញ្ញៅ ស្រុកសន្ទុក ខេត្ត កំពង់ធំ**

***

**រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ១៦ ខែ កក្កដា ១៩៩៦ ស្ដីពី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្ដីពីការបើក សាលារៀនមធ្យមសិក្សាកំរិត១-កំរិត២ ។

-យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំញ្ញៅ ស្រុកសន្ទុក និងឃុំត្នោតជុំ ស្រុកបារាយណ៍ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាលខេត្តកំពង់ធំ ។

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ “ញ្ញៅ” ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ម៉ុក ម៉ន

★★★